ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ
នាយកដ្ឋានសុខាភិបាល

# សេចក្តីណែនាំ
## ស្តីពី
## ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ១៩

នាយកដ្ឋានសុខាភិបាល ក្រសួងការពារជាតិ សូមជម្រាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានស្ថាប័ន មេបញ្ជាការគ្រប់កងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ មេត្តាជ្រាបថា នៅក្នុងសភាពការណ៍បច្ចុប្បន្ន ករណីរីករាលដាលនៃការឆ្លងវីរុសកូវីដ១៩ក្នុងព្រះរាជាណាចក្រកម្ពុជា មានការកើនឡើងយ៉ាងឆាប់រហ័សគួរឲ្យកត់សម្គាល់ ។

ជាការរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្រសួងសុខាភិបាលក្នុងការចាត់វិធានការ បង្កើនកិច្ចការពារ ការបង្ការ និងការទប់ស្កាត់ការរាលដាលនៃការឆ្លងមេរោគកូវីដ១៩ នៅក្នុងស្ថាប័ន និងកងឯកភាពរបស់ខ្លួន នាយកដ្ឋានសុខាភិបាល ក្រសួងការពារជាតិ សូមចេញសេចក្តីណែនាំជូនដល់គ្រប់ស្ថាប័ន កងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ ដូចតទៅ ៖

១.ណែនាំដល់នាយទាហាន នាយទាហានរង និងពលទាហាន ព្រមទាំងក្រុមគ្រួសារទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាពតាមសារាចរណែនាំលេខ០១សរណន ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ ស្តីពីវិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ របស់រាជរដ្ឋាភិបាល និងសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ដែលបានចេញជាបន្តបន្ទាប់ ។

២.សហការឲ្យបានជិតស្និទ្ធជាមួយមន្ទីរសុខាភិបាលរាជធានី ខេត្ត ដែលជាសេនាធិការរបស់ក្រសួងសុខាភិបាល ដើម្បីចាត់វិធានការបង្កើនកិច្ចការពារ អប់រំ បង្ការ និងទប់ស្កាត់ការរីករាលដាលនៃការឆ្លងវីរុសកូវីដ១៩ នៅផ្ទៃក្នុងស្ថាប័ន អង្គភាពរបស់ខ្លួន តាមរយៈការធ្វើអនាម័យ លាងដៃឲ្យបានញឹកញាប់ សម្អាតបន្ទប់បំពេញការងារ បន្ទប់ស្នាក់នៅ បន្ទប់ទឹក បោកគក់សម្លៀកបំពាក់ និងគ្រឿងបរិក្ខារប្រើប្រាស់ផ្សេងៗ ឲ្យបានជាប់ជាប្រចាំ ។

៣.ពិនិត្យឃើញរោគសញ្ញាណាមួយដែលមានភាពសង្ស័យ ដូចជា ឡើងកំដៅ ក្អក ឈឺបំពង់ក ហត់ ពិបាកដកដង្ហើម ឬបញ្ហាសុខភាពផ្សេងៗ ត្រូវរាយការណ៍ជាបន្ទាន់ទៅកាន់ទូរស័ព្ទទាន់ហេតុការណ៍១១៥ ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ឬមន្ទីរពេទ្យបង្អែកដែលនៅជិតផ្ទះ ឬមន្ទីរពេទ្យយោធានៅតំបន់ប្រតិបត្តិការសឹក កងពល យោធភូមិភាគ និងមន្ទីរពេទ្យព្រះកេតុមាលា តាមរយៈទូរស័ព្ទទំនាក់ទំនងលេខ ០៣១ ៣៤៥ ១១១៥/ ០៣១ ៣៤៥ ១១១៦/ ០៣១ ៣៤៥ ១១១៧/ ០៣១ ៣៤៥ ១១១៨/ ០៣១ ៣៤៥ ១១១៩ ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ស្ថាប័ន កងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ ចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព ។

ថ្ងៃអង្គារ ៩រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០

**នាយក**

ឧត្តមសេនីយ៍ឯក. គង់_សាលី